សាំងចច ( St George Hospital ) ទូរស័ព្ទ ( 02 ) 350 2742 , មន្ទីរពេទ្យ ( Livingstone Road Clinic ), នៅ Marrickville ទូរស័ព្ទ ( 02 ) 560 3057 , មន្ទីរពេទ្យនៅ Holden Street Centre, Gosford ទូរស័ព្ទ ( 043 ) 202 114 , និងមន្ទីរពេទ្យ ផតខេមប្ល ( Port Kembla Hospital ) ទូរស័ព្ទ ( 042 ) 762 399 ។ បើចាំបាច់គេអាចរកអ្នកបកប្រែជូន សូមអ្នកប្រាប់ឲ្យគេដឹងជាមុននៅពេលអ្នកធ្វើការណាត់ជួប ។ នៅមណ្ឌលសុខភាពផ្នែកកាមទាំងនេះក៏មានក្រដាស់ជាភាសាអង់គ្លេសស្តីពីជម្ងឺហឺបពីស្យនៅប្រដាប់បន្តពូជដែរ ៕

*********************


**NSW Multicultural Health Communication Service**

website: www.http://mhcs.health.nsw.gov.au

e-mail: mhcs@doh.health.nsw.gov.au

phone: (02) 9382 8111



KHMER
29 January 1996


multicultural communication

# អ្វីខ្លះដែលអ្នកត្រូវដឹងអំពីជម្ងឺ " ហឺបពីស្យ "

## What You Should Know About Herpes

NSW HEALTH
FOR A STATE OF BETTER HEALTH

# អ្វីខ្លះដែលអ្នកត្រូវដឹងអំពីជម្ងឺ " ហឺបពីស្ស "

## What You Should Know About Herpes

មានបុព្វហេតុល្អៗខ្លះដែលធ្វើឲ្យយើងម្នាក់ៗគួរដឹងអំពីជម្ងឺ ហឺបពីស្ស នៃប្រដាប់បន្តពូជ ( genital herpes ) ។ នៅក្នុងប្រទេសអូស្ត្រាលី ជម្ងឺឆ្លងពីការសេពកាមនេះជាជម្ងឺដ៏សាមញ្ញបំផុតមួយ ដែលមានឥទ្ធិពលដល់មនុស្សម្នាក់ក្នុងចំណោមមនុស្សប្រាំនាក់ដែលមានការសេពកាម ។ ក៏ប៉ុន្តែដោយសារមនុស្សភាគច្រើនមិនដឹងថាខ្លួនមានជម្ងឺនេះ ជននោះអាចចម្លងរោគនោះទៅអ្នកដ៏ទៃដោយមិនដឹងខ្លួន ។

**តើ ហឺបពីស្ស ជាអ្វី ?** វាជាមេរោគសាមញ្ញមួយដែលអាចបណ្តាលឲ្យឡើងពងកន្ទួលៗនៅលើប្រដាប់បន្តពូជ ហើយនិងមានរោគសញ្ញាផ្សេងទៀតដូចជារមាស់ ការឈឺឆៀបៗ និងដូចជាមិនស្រួលក្នុងខ្លួន ។ ជារឿយៗ ពងកន្ទួលៗនិងរោគសញ្ញាផ្សេងទៀតនោះច្រើនកើតមានឡើងក្នុងរយៈ ២ ទៅ ២០ ថ្ងៃក្រោយពីការឆ្លងជម្ងឺនេះ ក៏ប៉ុន្តែមិនមែនគ្រប់គ្រាហ៍នោះឡើយ ។ ជួនកាលវាអាចអស់ពេលជាច្រើនខែ ឬឆ្នាំទម្រាំឃើញមានរោគសញ្ញាក្រោយពីការឆ្លងមេរោគ ។ ចូរអ្នកសន្និដ្ឋានមើល ប្រសិនបើមានអ្នកណាម្នាក់ដែលឆ្លងមេរោគនេះពីដៃគូកាលពីប៉ុន្មានឆ្នាំមុន ហើយទើបតែមានរោគសញ្ញាហឺបពីស្សចេញនៅពេលប្រាស្រ័យទាក់ទងជាមួយដៃគូថ្មី ។ ដៃគូថ្មីនោះអាចយល់ច្រឡំថា ដៃគូរបស់ខ្លួនមានរួមមេត្រីជាមួយជាមួយអ្នកផ្សេងទៀត ។

**តើជម្ងឺហឺបពីស្សឆ្លងតាមរបៀបណា ?** ជម្ងឺនេះឆ្លងតាមការប៉ះរួមមេត្រីជាមួយជនដែលមានមេរោគហឺបពីស្ស ហើយអាចបណ្តាលឲ្យកើតពងកន្ទួលនៅលើប្រដាប់បន្តពូជ និងពងខ្ទុះក្នុងមាត់ ។ ប្រជាជនអាចឆ្លងហឺបពីស្សទៅប្រដាប់បន្តពូជតាមការរួមមេត្រីជាមួយជនដែលមានហឺបពីស្សនៅប្រដាប់បន្តពូជ ឬតាមការសេពកាមតាមមាត់ជាមួយជនដែលមានពងខ្ទុះក្នុងមាត់ ។

យើងមិនអាចតែងតែដឹងថាតើជនណាមានកើតហឺបពីស្ស ឬអត់នោះទេ ។ អ្នកជម្ងឺអាចមានមេរោគនោះហើយចម្លងទៅអ្នកដ៏ទៃ ទោះបីអ្នកនោះមានពងខ្ទុះ ឬអត់ក្តី ។

**តើជម្ងឺ ហឺបពីស្ស មានឥទ្ធិពលដល់សុខភាពយ៉ាងណាខ្លះ ?**

ជម្ងឺនេះមិនគំរាមកំហែងដល់ជីវិតនោះទេ ហើយវាក៏គ្មានឥទ្ធិពលដល់ភាពមានកូនឡើយ ។ ឥទ្ធិពលនៃជម្ងឺហឺបពីស្សមានដល់សុខភាពប៉ុនណា គឺយោងទៅតាមសាមុីខ្លួនម្នាក់ៗ ។ ឧទាហរណ៍ ចំពោះជនខ្លះ វាអាចចេញពងកន្ទួលៗ ៣-៤ ដងក្នុងមួយឆ្នាំ ហើយនិងធ្វើឲ្យរមាស់ ឈឺឆៀបៗ និងរំខានប៉ុណ្ណោះ ។ ចំពោះអ្នកខ្លះទៀតពងកន្ទួលៗនេះចេញតិចជាងនេះទៅទៀត ។ ក៏ប៉ុន្តែចំពោះជនខ្លះ អាចចេញពងកន្ទួលច្រើនជាងនេះ ហើយធ្វើឲ្យមិនស្រួលខ្លួន និងឈឺផ្សាទៀតផង ។

**តើគេអាចការពារ ហឺបពីស្ស តាមរបៀបណា ?** ស្រោមលិង្គអាចជួយការពារបាន ទោះបីមិនពេញលេញក្តី ។ នេះក៏ដោយសារមេរោគហឺបពីស្សអាចឆ្លងទៅប្រដាប់បន្តពូជ ទៅគូថនិងទៅភ្លៅផង ។ របៀបការពារម្យ៉ាងទៀតគឺការតមមិនរួមមេត្រីនៅពេលមានចេញរោគសញ្ញាដូចជា ការឈឺឆៀបៗ រមាស់ ពងកន្ទួលៗ ឬពងខ្ទុះ ។ ក៏ប៉ុន្តែដោយសារអ្នកជម្ងឺខ្លះគ្មានកើតរោគសញ្ញាឲ្យដឹងនោះ គេក៏អាចឆ្លងមេរោគនេះពីអ្នកជម្ងឺ ដែលមិនទាំងដឹងថាខ្លួនឯងមានជម្ងឺនេះផង ។

**តើគេអាចព្យាបាល ហឺបពីស្ស បានឬទេ ?** បញ្ហានៃជម្ងឺនេះគឺថា តែកាលណាជនណាឆ្លងជម្ងឺនេះ ជននោះនឹងមានជម្ងឺនេះរហូត ។ ក៏ប៉ុន្តែគេមានថ្នាំព្យាបាលហឺបពីស្ស ដើម្បីបន្ថយកុំឲ្យសូវចេញពងកន្ទួល និងពងខ្ទុះ ហើយនិងកុំឲ្យមានសភាពធ្ងន់ធ្ងរពេក ។

**តើប្រជាជនអាចទៅពិនិត្យ និងព្យាបាលដោយសម្ងាត់នៅទីកន្លែងណា ?** គឺនៅតាមមណ្ឌលសុខភាពផ្នែកកាម Sexual Health Centre នានា ដែលផ្តល់ការបំរើដោយគ្មានយកតម្លៃ ហើយដែលអ្នកមិនចាំបាច់ប្រាប់ឈ្មោះ ឬប្រើកាត មេឌីឃែរ ឡើយ ។ នៅតាមមន្ទីរពេទ្យខ្លះក៏មានមណ្ឌលសុខភាព Sexual Health Centre ដូចជានៅមន្ទីរពេទ្យស៊ីដនី Sydney Hospital , Macquarie Street, Sydney, ទូរស័ព្ទ ( 02 ) 382 7440 ពីម៉ោង ៨ កន្លះព្រឹកទៅម៉ោង ៧ ល្ងាចរាល់ថ្ងៃច័ន្ទ, អង្គារ, ព្រហស្បតិ៍, សុក្រ និងពីម៉ោង ២ កន្លះល្ងាចទៅម៉ោង ៧ ល្ងាចរាល់ថ្ងៃពុធ។ នៅតាមមន្ទីរពេទ្យឯទៀតខ្លះក៏មានមណ្ឌលសុខភាពផ្នែកកាមដែរ ដូចជានៅមន្ទីរពេទ្យលីវើរភូល ( Liverpool Hospital ) ទូរស័ព្ទ ( 02 ) 827 8022 , មន្ទីរពេទ្យប៉ារ៉ាម៉ាតា ( Parramatta Hospital ) ទូរស័ព្ទ ( 02 ) 635 6851, មន្ទីរពេទ្យ